**វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម**
**នៃរាជបណ្ឌិត្យសភាកម្ពុជា**

**អត្ថបទស្រាវជ្រាវ**

**ស្តីពី**

# «បញ្ហា និងដំណោះស្រាយទីផ្សារបន្លែនៅកម្ពុជា»

*បណ្ឌិត* **ឆេង វណ្ណារិទ្ធ**
*ប្រធានស្ដីទីវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម*

*មីនា ២០១៩*

# «បញ្ហា និងដំណោះស្រាយទីផ្សារបន្លែនៅកម្ពុជា»

*បណ្ឌិត **ឆេង វណ្ណារិទ្ធ***
*ប្រធានស្តីទីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

## សេចក្តីផ្តើម

ថ្វីបើប្រទេសកម្ពុជា ជាប្រទេសកសិកម្មខ្លាំងមួយក្នុងតំបន់អាស៊ីអាគ្នេយ៍ ប៉ុន្តែនាពេលបច្ចុប្បន្ន ប្រទេសនេះ ផលិតបន្លែមិនទាន់គ្រប់គ្រាន់តាមតម្រូវការក្នុងស្រុករបស់ខ្លួននៅឡើយ ដែលជាហេតុឱ្យមាន ការនាំចូលបន្លែពីប្រទេសជិតខាងច្រើន លើសពាក់កណ្តាលនៃតម្រូវការរបស់ខ្លួន។ ប្រសិនបើស្ថានភាព នៃការផលិតបន្លែក្នុងស្រុកនឹងស្ថិតក្នុងសភាពដូចនេះជាបន្តទៀត នោះប្រទេសកម្ពុជានឹងបន្តនាំចូលបន្លែ កាន់តែច្រើនថែមទៀតពីមួយឆ្នាំ ទៅមួយឆ្នាំ ពីប្រទេសថៃ និង វៀតណាម ។

គប្បីកត់សម្គាល់ថា ភាពមិនគ្រប់គ្រាន់នៃការផ្គត់ផ្គង់បន្លែក្នុងស្រុក ហើយបង្ខំឱ្យនាំចូលពីក្រៅ ប្រទេស វាមិនត្រឹមតែជាលំហូរចេញនៃរូបិយវត្ថុជាតិប៉ុណ្ណោះទេ តែវាថែមទាំងមានឥទ្ធិពលអវិជ្ជមានដល់ សន្តិសុខសេដ្ឋកិច្ច និងសង្គមផងដែរ ជាពិសេស បន្លែនាំចូលពីប្រទេសវៀតណាមដែលត្រូវបានជាប់ឈ្មោះ ក្នុងបញ្ជីរបស់សហភាពអឺរ៉ុប ថាជាផលិតផលប្រើប្រាស់ថ្នាំគីមីធ្វើឱ្យខូចសុខភាពអ្នកប្រើប្រាស់។

ប្រធានបទនៃការស្រាវជ្រាវនេះ នឹងវិភាគបញ្ហាទីផ្សារបន្លែនាពេលបច្ចុប្បន្ននៅប្រទេសកម្ពុជា និង បង្ហាញនូវវិធានការលើកកម្ពស់ការផ្គត់ផ្គង់បន្លែដែលផលិតដោយកសិករក្នុងស្រុក ដើម្បីបញ្ចៀសបច្ច័យ អវិជ្ជមានទៅលើសេដ្ឋកិច្ច និង សង្គមកម្ពុជា។

### ១- ស្ថានភាពទូទៅ

ទោះបីប្រទេសកម្ពុជាពឹងផ្អែកលើវិស័យកសិកម្មមួយចំណែកធំយ៉ាងណាក្តី ក៏បច្ចុប្បន្ននេះប្រទេស នេះកំពុងជួបនឹងកង្វះខាតបន្លែសម្រាប់ផ្គត់ផ្គង់តម្រូវការក្នុងស្រុក ដែលជាហេតុឱ្យនាំចូលបន្លែពីប្រទេស ជិតខាងជារៀងរាល់ថ្ងៃ។ តាមការសិក្សាស្រាវជ្រាវពីប្រភពផ្សេងៗបានបង្ហាញឱ្យឃើញថា ប្រទេសកម្ពុជានាំ ចូលបន្លែពីក្រៅប្រទេសមានចំនួនប្រមាណជា២០០តោនទៅ៤០០តោនក្នុងមួយថ្ងៃៗសម្រាប់ផ្គត់ផ្គង់ទី ផ្សារក្នុងស្រុក ហើយបន្លែទាំងនោះភាគច្រើននាំចូលពីប្រទេសវៀតណាម ថៃ និង ចិន ដោយចំណាយ ថវិកាជាង២០០លានដុល្លារអាម៉េរិកក្នុងមួយឆ្នាំៗ[1]។ តាមរបាយការណ៍របស់អង្គការស្បៀងអាហារ និង កសិកម្មនៃអង្គការសហប្រជាជាតិបានបង្ហាញថា «បរិមាណបន្លែដែលផ្គត់ផ្គង់នៅកម្ពុជាមានប្រមាណជិត ១លានតោនក្នុង១ឆ្នាំៗ ដែលក្នុងនោះបរិមាណបន្លែផ្គត់ផ្គង់ក្នុងស្រុកមានត្រឹមតែ៤៤%ប៉ុណ្ណោះ ចំណែក

---

[1] https://thmeythmey.com/?page=detail&id=57231

ការនាំចូលមានរហូតដល់៥៦%»[2]។ ដោយឡែកនៅរាជធានីភ្នំពេញ បន្លែចំនួន៧០ភាគរយ ជាបន្លែនាំពីប្រទេសថៃ និងវៀតណាម រីឯបន្លែរបស់ប្រជាកសិករកម្ពុជាមានតែប្រមាណ៣០ភាគរយប៉ុណ្ណោះ។

មូលហេតុនៃការនាំចូលបន្លែយ៉ាងសន្ធឹកសន្ធាប់បែបនេះពីប្រទេសជិតខាង ដោយសារតែបន្លែនាំចូលទាំងនោះមានតម្លៃថោក ស្របពេលដែលបន្លែរបស់កសិករខ្មែរមិនគ្រប់គ្រាន់តាមតម្រូវការទីផ្សារ ឬមានថ្លៃខ្ពស់ជាងបន្លែនាំចូល(កសិករទាមទារតម្លៃលក់បន្លែខ្ពស់ជាង ពី២០ទៅ៣០ភាគរយ[3])។

កត្តាដែលធ្វើឱ្យការផ្គត់ផ្គង់បន្លែក្នុងស្រុកមិនគ្រប់គ្រាន់តាមតម្រូវការ ព្រមទាំងថ្លៃខ្ពស់ជាងថ្លៃបន្លែនាំចូលពីប្រទេសជិតខាង រួមមានៈ

**១- បច្ចេកទេសផលិតកម្មមានកម្រិតទាប**

កសិករខ្មែរធ្វើកសិកម្មតាមបែបយថាផល ប្រើប្រាស់សារធាតុគីមី ខ្វះបច្ចេកទេស កង្វះការរៀបចំប្រពន្ធជាវាសាស្ត្រ គ្មានចំណេះដឹងក្នុងការប្រើប្រាស់ដី ទឹក ជី ពូជ ជាដើម ដែលជាហេតុទទួលបានទិន្នផលទាប ធ្វើឱ្យថ្លៃដើមផលិតកម្មខ្ពស់។

**២- ថ្លៃវត្ថុធាតុដើមខ្ពស់**

ប្រេងឥន្ធនៈ ជី-ថ្នាំកសិកម្មឡើងថ្លៃខ្ពស់ និងលឿនជាងថ្លៃបន្លែនៅលើទីផ្សារ ជាហេតុធ្វើឱ្យថ្លៃបន្លែដែលផលិតក្នុងស្រុកមិនអាចលក់បានតាមថ្លៃបន្លែនាំចូល។

**៣- កង្វះដើមទុន**

កសិករភាគច្រើនមិនមានដើមទុនគ្រប់គ្រាន់ ចំណែកប្រាក់កម្ចីមានអត្រាខ្ពស់ មិនអាចផ្គត់ផ្គង់ប្រាក់ចំណេញដល់កសិករដាំបន្លែ។

**៤- បញ្ហាទីផ្សារ**

ពេលរដូវប្រមូលផលមកដល់ធ្វើឱ្យថ្លៃបន្លែក្នុងស្រុកធ្លាក់ចុះ ហួសលទ្ធភាពដែលអ្នកដាំបន្លែអាចលក់បាន។ ម្យ៉ាងវិញទៀតពេលដែលកសិករដាំបន្លែបានផល ពួកគាត់មិនដឹងថាតើលក់ឱ្យអ្នកណា? លក់នៅទីណា? លក់ចំនួនប៉ុន្មាន? ជាដើម ពោលគឺគ្មានទីផ្សារ ។

## ២- ការវិភាគទីផ្សារបន្លែតាមរយៈក្រាហ្វិក

មុនឈានដល់ការវិភាគតាមរយៈក្រាហ្វិក យើងគប្បីយល់ន័យ អ្វីជាទីផ្សារ(market) អ្វីជាតម្រូវការ(demand) អ្វីជាការផ្គត់ផ្គង់(supply) និង អ្វីដែលហៅថា ថ្លៃសមតាឬថ្លៃទីផ្សារ(equilibrium price) ។

[2] http://www.freshnewsasia.com/index.php/en/localnews/52946-2017-04-21-11-13-37.html

[3] https://www.postkhmer.com/%E1%9E%9F%E1%9F%81%E1%9E%8A%E1%9F%92%E1%9E%8B%E1%9E%80%E1%9E%B7%E1%9E%85%E1%9F%92%E1%9E%85/%E1%9E%94%E1%9E%89%E1%9F%92%E1%9E%A0%E1%9E%B6%E1%9E%94%

ក្នុងន័យបច្ចេកសព្ទវិទ្យាសាស្ត្រសេដ្ឋកិច្ច «ទីផ្សារ»(market) គឺជាស្ថាប័នឬយន្តការទាំងឡាយ ដែលផ្សារភ្ជាប់រវាងអ្នកទិញ(អ្នកមានតម្រូវការ) និងអ្នកលក់(អ្នកផ្គត់ផ្គង់) នូវផលិតផលឬសេវាជាក់លាក់ណាមួយ[4]។ «តម្រូវការ»(demand) គឺបរិមាណទំនិញឬសេវា ដែលអ្នកប្រើប្រាស់ត្រៀមនិងមានលទ្ធភាពទិញតាមថ្លៃជាក់លាក់មួយនិងក្នុងពេលវេលាជាក់លាក់មួយ។ ចំណុចនេះយើងឃើញពាក្យ «ត្រៀម» និង «មានលទ្ធភាព» ដែលមានន័យថា «ត្រៀម» គឺគ្រាន់តែមានបំណង ប៉ុន្តែអាស្រ័យលើ «លទ្ធភាព» ថាតើមានប្រាក់គ្រប់គ្រាន់សម្រាប់ទិញទំនិញឬសេវានោះដែរឬទេ?។ ដូច្នេះ ត្រូវតែមានបំណងបូកជាមួយនឹងលទ្ធភាព(ប្រាក់)ទើបគេហៅថា «មានតម្រូវការ» បើមានតែបំណង តែ«គ្មានលទ្ធភាព»(គ្មានប្រាក់) គឺមានន័យថា «គ្មានតម្រូវការ»។ ចំណែកឯការផ្គត់ផ្គង់(supply) គឺបរិមាណទំនិញឬសេវា ដែលអ្នកលក់(អ្នកផ្គត់ផ្គង់)ត្រៀមនិងមានលទ្ធភាពលក់តាមថ្លៃជាក់លាក់មួយនិងក្នុងពេលវេលាជាក់លាក់មួយ។ ចំណុចនេះយើងឃើញពាក្យ «ត្រៀម»និង«មានលទ្ធភាព» ដូចគ្នាក្នុងនិយមន័យតម្រូវការដែរ ប៉ុន្តែមានន័យខុសគ្នា ដោយ«ត្រៀម» គឺគ្រាន់តែមានបំណង ប៉ុន្តែអាស្រ័យលើ «លទ្ធភាព» ថាតើថ្លៃដែលលក់ទំនិញនោះអាចទូទាត់ចំណាយថ្លៃដើមផលិតកម្ម ហើយទទួលបានប្រាក់ចំណេញដែរឬទេ?។ បើមិនបានទទួលផលចំណេញគឺមិនលក់ឬមិនផលិត តែបើបានផលចំណេញ គឺនឹងខិតខំលក់ឬផលិតកាន់តែច្រើន។ ដូច្នេះការផ្គត់ផ្គង់គឺអាស្រ័យពីប្រាក់ចំណេញ តែប្រាក់ចំណេញគឺអាស្រ័យពីថ្លៃលក់ ហើយថ្លៃលក់គឺអាស្រ័យពីថ្លៃដើមផលិតកម្ម ចំណែកឯថ្លៃទំនិញនៅលើទីផ្សារគឺអាស្រ័យពីតម្រូវការនិងការផ្គត់ផ្គង់។ «ថ្លៃសមតាឬថ្លៃទីផ្សារ»(equilibrium price, market price)គឺថ្លៃទំនិញឬសេវាដែលត្រូវបានកំណត់ដោយតម្រូវការនិងការផ្គត់ផ្គង់នៅលើទីផ្សារប្រកួតប្រជែង ហើយដែលបរិមាណតម្រូវការនិងការផ្គត់ផ្គង់ស្មើគ្នា។

បន្ទាប់ពីកំណត់និយមន័យទីផ្សារ(market) តម្រូវការ(demand) ការផ្គត់ផ្គង់(supply) និង «ថ្លៃសមតាឬថ្លៃទីផ្សារ»(equilibrium price, market price)យើងសាកល្បងរកចម្លើយ៖

### *ទីមួយ តើមូលហេតុអ្វីបានជាបន្លែផលិតនៅក្នុងស្រុកថ្លៃខ្ពស់?*

នៅលើរូប១ ការកើនឡើងចំនួនអ្នកប្រើប្រាស់(កំណើនប្រជាពលរដ្ឋនិងចំនួនទេសចរបរទេស)ធ្វើឱ្យតម្រូវការបន្លែ ដែលជាអាហារចាំបាច់ត្រូវបានកើនឡើងសមមាត្រនឹងចំនួននេះ(ពី$D_1$ទៅ$D_2$)។ ខណៈដែលតម្រូវការបន្លែកើនឡើងតាមកំណើនចំនួនអ្នកប្រើប្រាស់ គ្រាដែលការផ្គត់ផ្គង់បន្លែផលិតក្នុងស្រុកគ្មានការប្រែប្រួល(ជួនកាលបរិមាណបន្លែផលិតក្នុងស្រុកធ្លាក់ចុះបណ្តាលពីធាតុអាកាស)($S_f$) នោះធ្វើឱ្យថ្លៃបន្លែដែលផលិតក្នុងស្រុកឡើងពី$P_1$ទៅ $P_2$។

---

4 CAMPBELL R. McCONNELL and STANLEY L. BRUE, ECONOMICS, PRINCIPLES, PROBLEMS, AND POLICIES, Thirteenth edition, GLOSSARY, G-18.

# តម្រូវការ និង ការផ្គត់ផ្គង់បន្លែ




**រូប ១. ការកើនឡើងនៃតម្រូវការបន្លែ ក្នុងករណីការផ្គត់ផ្គង់នៅនឹង**

$P_1$ , $P_2$ - ថ្លៃបន្លែនៅលើទីផ្សារ

$S_f$ - ការផ្គត់ផ្គង់បន្លែនៅលើទីផ្សារ ដែលបរិមាណនៅនឹង

$D_1$ , $D_2$ - តម្រូវការបន្លែនៅលើទីផ្សារក្នុងស្រុក

ទីផ្សារបន្លែក្នុងករណីតម្រូវការកើនឡើង ប៉ុន្តែការផ្គត់ផ្គង់នៅនឹង(ពុំមានលទ្ធភាពកើនឡើងតាមតម្រូវការ) នោះធ្វើឱ្យថ្លៃបន្លែនៅលើទីផ្សារឡើងពី $P_1$ ទៅ $P_2$។

### *ទីពីរ តើហេតុអ្វីបានជាទីផ្សារបន្លែនៅប្រទេសកម្ពុជាត្រូវបានបំពេញដោយបន្លែនាំចូលពីបរទេស?*

នៅលើរូប២ យើងឃើញថា តម្រូវការបន្លែនៅលើទីផ្សារក្នុងស្រុក គឺនៅចំណុច B ដែលមានបរិមាណ $Q_e$។ ប៉ុន្តែការផ្គត់ផ្គង់បន្លែដែលផលិតក្នុងស្រុក $S_d$ បានត្រឹមតែនៅលើចំណុច A ក្នុងកម្រិតថ្លៃស្មើនឹង $P_d$(កសិករដាំបន្លែមិនអាចលក់ផលិតផលរបស់ខ្លួនទាបជាង$P_d$ បានឡើយ មូលហេតុពួកគេមិនទទួលបានផលចំណេញ ដោយហេតុចំណាយថ្លៃដើមផលិតកម្មខ្ពស់) ដែលបរិមាណការផ្គត់ផ្គង់បានត្រឹមចំណុច $Q_d$ តែប៉ុណ្ណោះ។ ដោយតម្រូវការបន្លែក្នុងស្រុកច្រើនជាងការផ្គត់ផ្គង់ក្នុងស្រុក ហើយម្យ៉ាងទៀតនៅប្រទេសជិតខាងគេចំណាយថ្លៃដើមផលិតកម្មទាបជាងនៅក្នុងប្រទេសកម្ពុជា នោះគេអាចនាំចូលមកដើម្បីបង្គ្រប់តម្រូវការបន្លែក្នុងប្រទេសកម្ពុជា រហូតដល់ $S_e$ (ប្រមាណជា២០០តោនទៅ៤០០តោនក្នុងមួយថ្ងៃៗ)លក់តាមថ្លៃដែលទាបជាង$P_d$ ពោលគឺថ្លៃបន្លែនៅលើទីផ្សារក្នុងស្រុកស្មើនឹង $P_e$ ។

សរុបសេចក្តីមក ការផ្គត់ផ្គង់បន្លែដែលផលិតនៅក្នុងស្រុកគឺបានត្រឹមតែពី 0 ទៅ$Q_d$(៤៤% នៃតម្រូវការបន្លែសរុបក្នុងស្រុក)ហើយពី $Q_d$ ទៅ $Q_e$ (៥៦% នៃតម្រូវការបន្លែសរុបក្នុងស្រុក ស្មើនឹងប្រមាណជា ២០០តោនទៅ៤០០តោនក្នុងមួយថ្ងៃៗ) ត្រូវបានបំពេញដោយបន្លែនាំចូលមកពីប្រទេសថៃ និង វៀតណាម ដោយចំណាយថវិកាប្រមាណជាង២០០លានដុល្លារអាម៉េរិកក្នុងមួយឆ្នាំៗ។




**រូប ២. តម្រូវការ និង ការផ្គត់ផ្គង់បន្លែ នៅលើទីផ្សារនៃប្រទេសកម្ពុជា(សមត្តិកម្ម)**

*$P_e$ -ថ្លៃសមតាបន្លែនៅលើទីផ្សារនៃប្រទេសកម្ពុជា, $P_d$ -ថ្លៃបន្លែដែលផលិតក្នុងស្រុក*
*$S_e$ - បរិមាណសមតាការផ្គត់ផ្គង់បន្លែនៅលើទីផ្សារនៃប្រទេសកម្ពុជា*
*$S_d$- ការផ្គត់ផ្គង់បន្លែដែលផលិតក្នុងស្រុក*
*A -ចំណុចសមតាតម្រូវការ និង ការផ្គត់ផ្គង់បន្លែដែលផលិតក្នុងស្រុក*
*B-ចំណុចសមតាតម្រូវការ និង ការផ្គត់ផ្គង់បន្លែនៅលើទីផ្សារនៃប្រទេសកម្ពុជា*
*0-$Q_d$ - បរិមាណបន្លែដែលផលិតនៅប្រទេសកម្ពុជា*
*$Q_d$ – $Q_e$ - បរិមាណបន្លែដែលត្រូវបាននាំចូលដើម្បីបំពេញតម្រូវការក្នុងស្រុក(ប្រទេសកម្ពុជា) ($D_d$) ពេលដើម្បីឱ្យមានសមតាតម្រូវការ និង ការផ្គត់ផ្គង់បន្លែនៅលើទីផ្សារប្រទេសកម្ពុជា។*

## ៣- វិធីដោះស្រាយបញ្ហាការផ្គត់ផ្គង់បន្លែនៅទីផ្សារក្នុងស្រុក (ទ្រឹស្តី)

### *តើត្រូវបង្កើនការផ្គត់ផ្គង់បន្លែក្នុងស្រុក ដើម្បីជំនួសការនាំចូលមកពីខាងក្រៅ?*

ក្នុងប្រវត្តិសាស្ត្រនយោបាយសេដ្ឋកិច្ចនៃប្រទេសជឿនលឿន គឺមានវិធានការដែលអាចកែប្រែក្នុងការផ្គត់ផ្គង់(changes in supply) ឬ កែប្រែក្នុងតម្រូវការ(changes in demand)នៃទំនិញឬសេវាជាក់លាក់ណាមួយ ដែលគេហៅថា «កត្តាសម្រេចនៃការផ្គត់ផ្គង់»(determinants of supply)និង «កត្តាសម្រេចនៃតម្រូវការ»(determinants of demand)។

ដោយបញ្ហាទីផ្សារបន្លែនៅកម្ពុជាទាក់ទងការផ្គត់ផ្គង់(supply)ដូច្នេះពេលនេះយើងពិនិត្យ«កត្តាសម្រេចនៃការផ្គត់ផ្គង់»(determinants of supply)។

ក្នុងចំណោម «កត្តាសម្រេចនៃការផ្គត់ផ្គង់»(determinants of supply) មាន៖

**១- ថ្លៃលើធនធាន**(resource prices)

ការបញ្ចុះថ្លៃប្រេងឥន្ធនៈ ជី ពូជ ធ្វើឱ្យការផ្គត់ផ្គង់បន្លែកើនឡើង (ពី$S_1$ទៅ$S_2$រូប៣) ផ្ទុយមកវិញ ការឡើងថ្លៃប្រេងឥន្ធនៈ ជី ពូជ ធ្វើឱ្យការផ្គត់ផ្គង់បន្លែថយចុះ (ពី $S_1$ ទៅ $S_3$រូប៣)

**២- បច្ចេកវិទ្យា**(technology)

ការប្រើប្រាស់ប្រព័ន្ធជាវាសាស្រ្តទំនើប ការជ្រើសរើសពូជ ជី ថ្នាំកសិកម្ម គ្រឿងយន្តកសិកម្ម ។ល។ ធ្វើឱ្យការផ្គត់ផ្គង់បន្លែកើនឡើង( ពី $S_1$ទៅ$S_2$រូប៣)។ ផ្ទុយមកវិញ ការប្រើប្រាស់ច្ចេកវិទ្យាហួសសម័យ វាធ្វើឱ្យចំណាយថ្លៃដើមផលិតកម្មកាន់តែខ្ពស់ ជាហេតុឱ្យការផ្គត់ផ្គង់បន្លែថយចុះ( ពី $S_1$ ទៅ $S_3$ រូប៣)។

**៣- ពន្ធនិងការឧបត្ថម្ភធន**(taxes and subsidies)

ការឧបត្ថម្ភធន គឺជាការកាត់បន្ថយចំណាយថ្លៃដើមផលិតកម្ម ដែលធ្វើឱ្យផលិតករអាចទទួលបានផលចំណេញកាន់តែច្រើន និងមានលទ្ធភាពប្រកួតប្រជែងនៅលើទីផ្សារផលិតផលរបស់ខ្លួន ហើយធ្វើឱ្យការផ្គត់ផ្គង់បន្លែកើនឡើង(ពី$S_1$ទៅ$S_2$រូប៣)។ ផ្ទុយមកវិញ ការយកពន្ធគឺជាបន្ទុកកាន់តែច្រើនក្នុងចំណាយថ្លៃដើម ដែលធ្វើឱ្យផលិតករគ្មានឆន្ទៈផលិត នាំឱ្យការផ្គត់ផ្គង់បន្លែថយចុះ(ពី$S_1$ទៅ$S_3$រូប៣)។

**៤- ថ្លៃលើទំនិញដទៃ**(prices of other goods)

ថ្លៃលូធ្លាក់ចុះ ធ្វើឱ្យការផ្គត់ផ្គង់បន្លែកើនឡើង(ពី$S_1$ទៅ$S_2$រូប៣) ផ្ទុយមកវិញ លូឡើងថ្លៃ ធ្វើឱ្យការផ្គត់ផ្គង់បន្លែថយចុះ (ពី$S_1$ទៅ$S_3$រូប៣)។

**៥- ក្តីរំពឹងចាំ**(expectations)

ពេលដែលរំពឹងថា នាពេលខាងមុខបន្លែនឹងចុះថ្លៃ នោះធ្វើឱ្យការផ្គត់ផ្គង់បន្លែខណៈនេះកើនឡើង (ពី $S_1$ទៅ$S_2$រូប៣ )។ ផ្ទុយមកវិញ ពេលដែលរំពឹងថា នាពេលដ៏ឆាប់ខាងមុខថ្លៃបន្លែនឹងឡើងខ្ពស់ នោះពេលនេះ ការផ្គត់ផ្គង់បន្លែថយចុះ(ពី$S_1$ ទៅ$S_3$រូប៣)។

**៦- ចំនួនផលិតករឬចំនួនអ្នកលក់**(number of producers, or sellers )

ចំនួនអ្នកដាំបន្លែកាន់តែច្រើន នោះធ្វើឱ្យការផ្គត់ផ្គង់បន្លែកើនឡើង (ពី$S_1$ទៅ$S_2$រូប៣ )។ ផ្ទុយមកវិញចំនួនអ្នកដាំបន្លែថយចុះ នោះ ការផ្គត់ផ្គង់បន្លែនឹងថយចុះ (ពី$S_1$ទៅ$S_3$រូប៣)។




**រូប៣.ការប្រែប្រួលក្នុងការផ្គត់ផ្គង់**( Changes in Supply )

*មានកត្តាមួយចំនួនដែលមិនទាក់ទងនឹងថ្លៃបន្លែ ប៉ុន្តែធ្វើឱ្យការផ្គត់ផ្គង់បន្លែនោះ កើនឡើង( ពី $S_1$ ទៅ $S_2$ ឬ $Q_1$ ទៅ $Q_2$ )ឬ ធ្លាក់ចុះ( ពី$S_1$ ទៅ $S_3$ ឬ ពី $Q_1$ ទៅ $Q_3$ )។ កត្តាទាំងនោះរួមមាន៖ ១-ការប្រែប្រួលថ្លៃធនធាន ឬ ថ្លៃវត្ថុធាតុដើម, ២- ការរីកចម្រើននៃបច្ចេកវិទ្យា, ៣-ការកែប្រែពន្ធ និងឧបត្ថម្ភធន, ៤- ការកែប្រែថ្លៃលើទំនិញដទៃ, ៥- ការប្រែប្រួលក្តីរំពឹងទុក, ៦- ការកែប្រែចំនួនផលិតករ (អ្នកផ្គត់ផ្គង់ )។ ការកែប្រែការផ្គត់ផ្គង់ ពី ពី$S_1$ ទៅ $S_2$ ឬ ពី$S_1$ ទៅ $S_3$ ប៉ុន្តែថ្លៃគឺនៅនឹង( $P_f$ )។*

## សន្និដ្ឋាន

ស្ថានភាពទីផ្សារបន្លែបច្ចុប្បន្ននៅកម្ពុជា គឺមានសភាពធ្ងន់ធ្ងរ ដោយហេតុបន្លែជាង៥០ភាគរយត្រូវបាននាំចូលពីប្រទេសជិតខាង ហើយនឹងបន្តនាំចូលកាន់តែច្រើនថែមទៀត ពីមួយឆ្នាំទៅមួយឆ្នាំ ខណៈដែលកម្ពុជាមិនអាចបង្កើនការផ្គត់ផ្គង់ដោយខ្លួនឯងបាន។ បញ្ហានេះអាចប៉ះពាល់ដល់សន្តិសុខសេដ្ឋកិច្ច និងសង្គម ជាពិសេសបន្លែដែលនាំចូលដោយប្រើប្រាស់ថ្នាំគីមីធ្វើឱ្យខូចសុខភាពអ្នកប្រើប្រាស់ នៅពេលដែលកម្ពុជានៅខ្វះមន្ទីរពិសោធន៍សម្រាប់រកសារជាតុគីមី ដែលមានជាតិពុលកប់ក្នុងបន្លែ។

ទោះជាបែបនេះក្តី ប្រទេសកម្ពុជានៅមានសក្តានុពលជាច្រើន ដែលអាចបង្កើនការផ្គត់ផ្គង់បន្លែក្នុងស្រុក។ យើងនឹងបន្តការសិក្សាស្រាវជ្រាវ ស្វែងរកវិធីដោះស្រាយនូវបញ្ហាការផ្គត់ផ្គង់បន្លែនៅទីផ្សារក្នុងស្រុក( អនុវត្តជាក់ស្តែង )ហើយនឹងចុះផ្សាយក្នុងទស្សនាវដ្តីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា នៅក្នុងលេខបន្តបន្ទាប់ទៀត៕

## ឯកសារយោង


១. https://thmeythmey.com/?page=detail&id=57231

២. http://www.freshnewsasia.com/index.php/en/localnews/52946-2017-04-21-11-1337.html

៣. https://www.postkhmer.com/%E1%9E%9F%E1%9F%81%E1%9E%8A%E1%9F%92%E1%9E%8B%E1%9E%80%E1%9E%B7%E1%9E%85%E1%9F%92%E1%9E%85/%E1%9E%94%E1%9E%89%E1%9F%92%E1%9E%A0%E1%9E%B6%E1%9E%94%

៤. CAMPBELL R. McCONNELL and STANLEY L. BRUE, ECONOMICS, PRINCIPLES, PROBLEMS, AND POLICIES, Thirteenth edition, GLOSSARY, G-18.